# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Oct-2015, 13:31
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើលើកទីប្រាំមួយរបស់ នួន ជា ពាក់ព័ន្ធនឹងភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រំ ផល្លា

លីវ សុវណ្ណា

Doreen CHEN

Xiaoyang NIE

ផ្ញើជូន៖

**សហមេធាវី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**

Marie GUIRAUD

អនុលោមតាមមាត្រា ៨.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក សហមេធាវីការពារក្តីរបស់លោក នួន ជា (មេធាវីការពារក្តី) សូមដាក់ការឆ្លើយតបនេះទៅនឹងចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើលើកទីប្រាំមួយរបស់ នួន ជា ពាក់ព័ន្ធនឹងភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ (ហៅជាបន្តបន្ទាប់ថា "ការឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី" ឬ "ការឆ្លើយតប" និង "សំណើ")។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមក្នុងសំណុំរឿង ០០២/០១ (សាលក្រម)[1]។ នៅថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០១៤ មេធាវីការពារក្តីបានជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដែលមាន២២៣ មូលដ្ឋានក្នុងការប្តឹងសាទុក្ខ[2]។ ហើយនៅថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១៤ មេធាវីការពារក្តី បានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន (បណ្តឹងសាទុក្ខ)[3]។

២. នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់សំណើសុំលើកទីប្រាំមួយរបស់ខ្លួនស្នើសុំឲ្យមានការពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទិននឹងបណ្តឹងសាទុក្ខ[4]។ នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់

---

[1] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី០៧ ខែ សីហា ឆ្នាំ២០១៤ (សាលក្រម)។

[2] ឯកសារ **E313/1/1** "សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ២៩ កញ្ញា ២០១៤។

[3] ឯកសារ **F16** "បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី២៩ ធ្នូ ២០១៤ (បណ្តឹងសាទុក្ខ)។

[4] ឯកសារ **F2/8** "សំណើលើកទីប្រាំមួយរបស់ខ្លួនស្នើសុំឲ្យមានការពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ (សំណើលើកទីប្រាំមួយសុំភស្តុតាងបន្ថែម)។

ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់មេធាវីការពារក្តី[5]។ មេធាវីការពារក្តីគិតថានេះជាការចាំបាច់ក្នុងការឆ្លើយតបទៅនឹងចម្លើយតបនេះ។

## II. អំណះអំណាង

៣. ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងពីចំណុចសំខាន់បី។ ទីមួយខ្លួនបានលើកឡើងថា សំណើទាក់ទងនឹងបញ្ហាមួយដែលមិនបានជំទាស់នៅក្នុងបណ្តឹងសាទុក្ខ គឺសមាសភាពសហឧក្រិដ្ឋកម្មរួម ('JCE')[6]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានលើកឡើងថា សំណើមានបំណងជំទាស់ទៅនឹងការចោទប្រកាន់ នួន ជា ក្នុងឋានៈជាថ្នាក់ដឹកនាំមួយរូប[7]។ ជាចុងបញ្ចប់ចម្លើយតបដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងថា ភស្តុតាងដែលបានស្នើក្នុងសំណើមិនត្រូវបានទទួលយកនោះទេ ដោយសារតែមិនថិតនៅក្នុងវិសាលភាពសំណុំរឿង ០០២/០១[8]។

៤. ដើមបណ្តឹងរដ្ឋប្បវេណីគ្មានជំហរណាមួយឆ្លើយតបទៅនឹងសំណើនោះទេ។ ទោះជានៅក្នុងកាលៈទេសៈបែបណាក៏ដោយក៏អំណះអំណាងខាងលើគឺគ្មានទំនាក់ទំនង និងគួរតែពុំត្រូវបានពិចារណាដោយអង្គជំនុំជម្រះតុលាការកំពូល។

### ក. ដើមបណ្តឹងរដ្ឋប្បវេណីខកខានបង្ហាញអំពីជំហររបស់ខ្លួន

៥. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់យ៉ាងច្បាស់ជាច្រើនដងថា "ការអនុវត្តសិទ្ធិក្នុងការឆ្លើយតប [...] ត្រូវតែស្ថិតនៅក្រោមដែនកំណត់" ដោយបន្ថែមទៀតថា "ទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសារណាតបដែលបានស្នើឡើង ត្រូវតែទាក់ទិនទៅនឹងមូលហេតុនានា ដែលប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី"[9]។ អង្គជំនុំជម្រះសាលាដំបូង កត់សម្គាល់ថា "យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ

---

[5] ឯកសារ **F2/8/1** "ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើលើកទីប្រាំមួយរបស់ នួន ជា ពាក់ព័ន្ធនឹងភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ" ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០១៥ (ចម្លើយតបរបស់សហមេធាវីនាំមុខ)។

[6] ឯកសារ **F2/8/1**ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១៤ ដល់ ២៣។

[7] ឯកសារ **F2/8/1**ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២៤ ដល់ ២៨។

[8] ឯកសារ **F2/8/1**ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២៩ ដល់ ៣០។

[9] ឯកសារ **F10/2** "សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១៧។

ព្រហ្មទណ្ឌអន្តរជាតិដែលមានកន្លងមក បានកំរិតសិទ្ធិរបស់ជនរងគ្រោះយ៉ាងតឹងរ៉ឹងក្នុងការបញ្ចេញទស្សនៈរបស់ខ្លួន នៅក្នុងអំឡុងពេលជំនុំជម្រះ” ហើយបានសម្រេចស្រដៀងគ្នានេះថា “តម្រូវឱ្យមានការបកស្រាយក្នុងន័យចង្អៀតអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងនីតិវិធីចំពោះមុខ អវតក”[10]។

៦. មេធាវីការពារក្តីកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនបានព្យាយាមបង្ហាញថាសំណើប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ខ្លួននោះទេ។ ផ្ទុយទៅវិញខ្លួនគ្រាន់តែយោងទៅអំណះអំណាងនៅក្នុងចម្លើយតបកាលពីមុននៅក្នុងចម្លើយតបទៅនឹងសំណើសុំឱ្យមានការស៊ើបសួររបស់មេធាវីការពារក្តីទាក់ទិននឹងសក្ខីកម្មរបស់ សំ សិទ្ធី[11]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏ខកខានក្នុងការពន្យល់អំពីវិធីដែលអំណះអំណាងនៅក្នុងចម្លើយតបរបស់ខ្លួនកាលពីលើកមុនទាក់ទងនឹងបញ្ហានេះ។

៧. ដើមបណ្តឹងរដ្ឋប្បវេណីមិនបានពន្យល់អំពីរបៀបដែលសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ដោយសំណើ ដែលការពិតគឺស៊ីសង្វាក់ទៅនឹងការយល់ច្បាប់ខុសរបស់ខ្លួនអំពីតួនាទីជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អវតក។ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា “សំណើគឺមិនបានគោរពដល់តុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់” ដោយពិចារណាដល់ “ភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី” និងអំពី “សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានសាលក្រមក្នុងពេលវេលាសមស្រប”[12]។ ដើមបណ្តឹងរដ្ឋប្បវេណីមានការព្រួយបារម្ភ “អំពីវ័យចំណាស់របស់ជនជាប់ចោទ” អាស្រ័យហេតុនេះហើយព្រួយបារម្ភថា “សំណើ

---

[10] សំណុំរឿង ០០១ ឯកសារ **E72/3** “សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោសនឹងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ” ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ កថាខណ្ឌ ១៣ និង ៣៩។

[11] ឯកសារ **F2/8/1**ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ៣២។ សូមមើល **F28/1** “ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើសុំឱ្យស៊ើបអង្កេតរបស់ នួន ជា ទាក់ទិននឹង សំ សិទ្ធី” ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ៣៧ ដល់ ៤១។ **F28** “សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានាដែលពីពណ៌នានៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី” ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥។

[12] ឯកសារ **F28/1** ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤០ ដល់៤១។

នឹងស្រូបយកពេលវេលា និងធនធានរបស់អង្គជំនុំជម្រះ ចំពោះការស្វែងរកការពិតក្នុងពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីកំពុងរង់ចាំសាលក្រម"[13]។

៨. បើទោះជាការរង់ចាំដ៏អត់ធ្មត់របស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានមើលឃើញ តែខ្លួនមិនបានពន្យល់អំពីមូលដ្ឋានណាមួយអំពីជំហរនេះទេ។ មូលដ្ឋាននៃការពន្យល់របស់ខ្លួនគឺតែអំពីថាសំណើណាមួយដែលបានស្នើដោយភាគីនៅពេលនេះនឹងប៉ះពាល់*ដោយផ្ទាល់* *(ipso facto)* ទៅលើសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីដោយសារតែនឹងប៉ះពាល់ដល់កាលវិភាគសវនាការ។ ការបកស្រាយនេះមិនសមស្របទៅនឹងសេចក្ដីណែនាំយ៉ាងច្បាស់ថាជំហរនេះត្រូវតែសម្រេចតាមមួយករណីម្ដងដោយពិចារណាអំពីផលប៉ះពាល់ ដែលអំណះអំណាងជាក់លាក់ដែលលើកឡើងដោយមេធាវីការពារក្ដីអាចប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងរដ្ឋប្បវេណីគួរតែបង្ហាញអំពីវិធីដែលភស្តុតាងដែលបានស្នើសុំឲ្យទទួលយកនៅក្នុងសំណើរ ដោយផ្អែកលើកទស្សនៈរបស់ខ្លួនគឺប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ខ្លួន។

៩. មេធាវីការពារក្ដីសូមរំលឹកថា សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺនឹងត្រូវបានកំណត់អំពីតួនាទីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីនៅ អវតក គឺ "ស្វែងរកសំណង"[14] គឺមិនមែនការគ្រប់គ្រងកាលវិភាគនៃដំណើរការនីតិវិធីនោះទេ។ ដើមបណ្ដឹងរដ្ឋប្បវេណីខ្វះមូលដ្ឋានក្នុងចម្លើយតប ដោយសារតែសំណើមិនទាក់ទងនឹងសំណង ឬបញ្ហាផ្សេងទៀតអំពីផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

**ខ. មេធាវីការពារក្ដីពិតជាបានជំទាស់ទៅនឹងអត្ថិភាព និង និយមន័យសហឧក្រិដ្ឋកម្មរួម (JCE)**

១០. ចម្លើយតបដើមបណ្ដឹងរដ្ឋប្បវេណីអះអាងថា សំណើជំទាស់ទៅនឹងសមាសភាព ឬសមាជិកភាពរបស់ នួន ជា នៅក្នុងសហឧក្រិដ្ឋកម្មរួម ហើយដែលមេធាវីការពារក្ដីមិនបានលើកឡើង

---

[13] ឯកសារ **F28/1** ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ៣៨ ដល់៤១។

[14] សំណុំរឿង ០០១ ឯកសារ **E72/3** "សេចក្ដីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី" កថខណ្ឌ ២៥ ៣៣ និង ៤២។ ឯកសារ **E365/1** "សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំការបំភ្លឺលើវិសាលភាពនៃការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី" ២៥ កញ្ញា ២០១៥ កថាខណ្ឌ ១២ ដល់ ១៥។

នៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន[15]។ ទស្សនៈនៃអ្នកទម្រង់និយម ចាត់ទុកថា នេះជាការលើកឡើងមិនទំនង។ ដោយពិចារណាថា អង្គជំនុំជម្រះសាលាដំបូងកំណត់សហឧក្រិដ្ឋរួមក្នុងន័យទូលាយ ដោយបន្ដគោលបំណង "អនុវត្តបដិវត្តសង្គមនិយមឆាប់រហ័ស" ជាគោលបំណងដែលមិនមែនជាបំណងឧក្រិដ្ឋ[16] និងគំនិតដែលថា មេធាវីការពារក្ដីគួរតែជំទាស់អំពីសមាជិកភាពរបស់ នួន ជា នៅក្នុងបដិវត្តថា ជាការបំពានទៅនឹងសុភវិនិច្ឆ័យ។

១១. ការអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគឺបកស្រាយខុសទាំងសំណើនិង បណ្ដឹងសាទុក្ខ។ ការបង្កើតមូលដ្ឋានទី២០០ នៃបណ្ដឹងសាទុក្ខ គឺជាការពន្យល់មួយដោយខ្លួនឯង។ "អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងអង្គហេតុក្នុងការកំណត់អំពីសហឧក្រិដ្ឋកម្មរួមរបស់ បកក"។ បណ្ដឹងសាទុក្ខជំទាស់ទៅនឹងអត្ថិភាព និង និយមន័យសហឧក្រិដ្ឋកម្មរួម គឺមាននៅក្នុងធាតុផ្សំសំខាន់ទាំងអស់ ជាពិសេសនៅក្នុងគោលបំណងជាទូទៅទាក់ទងនឹងការចូលរួមក្នុងឧក្រិដ្ឋកម្ម[17]។ ផ្ទុយពីអំណះអំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី បណ្ដឹងសាទុក្ខបានលើកឡើងជាច្រើនដងថា ភស្តុតាងជាប់ទាក់ទងនឹងការបះបោរផ្ទៃក្នុង បកក គឺមានទំនាក់ទំនង និងត្រូវតែពិចារណាទទួលយក[18]។ តាមរយៈការជំទាស់គោលបំណងឧក្រិដ្ឋ "ជាទូទៅ" ដែល "បាន

---

[15] ឯកសារ **F2/8/1**ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១៤ ដល់ ១៦ និង២១។

[16] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" កថាខណ្ឌ ៧២២ ៧៧៧ ដល់ ៧៧៨៩។

[17] ឯកសារ **F16** បណ្ដឹងសាទុក្ខ កថាខណ្ឌ ៤៩៤ ដល់ ៤៩៨។

[18] ឯកសារ **F16**បណ្ដឹងសាទុក្ខ កថាខណ្ឌ ៣៥ ("ជម្លោះផ្ទៃក្នុង បកក បានបណ្ដាលឲ្យអ្នកដែលមានស័ក្ដិទូទាំងបក្សបែកខ្ញែកជាក្រុមតូចៗ" "ដីកាដំណោះស្រាយគ្មាននិយាយអ្វីសោះអំពីភស្តុតាងអាចរកបានជាច្រើន ដែលបក្សមានការបែកបាក់មានក្រុមបំបែកខ្លួនខ្លាំងដូចគ្នា ។ ការពិតដែលថា វៀតណាមបានគាំទ្រក្រុមផ្ដាច់ខ្លួនេះដើម្បីធ្វើសង្គ្រាមប្រឆាំងនឹង ប៉ុល ពត នួន ជា និងអ្នកដទៃទៀត"។ ការបោសសម្អាតនេះគឺជាលទ្ធផលមកពីជម្លោះប្រដាប់អាវុធនៅក្នុងបក្ស ដែលធ្វើឲ្យ ប៉ុល ពត និង នួន ជា ប្រឆាំងនឹងកម្មភិបាលដែលរំពឹងថា ជាអ្នកអនុវត្តគោលនយោបាយរបស់បក្ស")។ កថាខណ្ឌ ៥៧ ("សាក្សីភាគច្រើនបាននិយាយទៅកាន់ ថេត សម្បត្តិថាអំពីរបៀបដែល ប៉ុល ពត និង នួន ជា ត្រូវបានគេក្បត់ និង ប្រឆាំង ដោយអ្នកនៅក្រោមបង្គាប់នៅក្នុងបកក ដែលភាគច្រើនបានធ្វើដោយផ្ទាល់ខ្លួន")។ កថាខណ្ឌ ៨២ ("មេធាវីការពារក្ដីក៏បានស្នើសុំភស្តុតាងក្នុងចំណោមនោះភស្តុតាងបះបោររបស់កម្មាភិបាលទូទាំងបកក ប្រឆាំងនឹង ប៉ុល ពត និង នួន ជា។ កថាខណ្ឌ ២៤២ ("កម្មាភិបាលទូទាំងប្រទេស "តាមពិតទៅភាគច្រើន" ក្បត់ និងប្រឆាំងនឹង ប៉ុល ពត ដោយសម្ងាត់។ កថាខណ្ឌ៤៦២ ("ជំហរដ៏យូររបស់របស់មេធាវីការពារក្ដីរបស់ នួន ជា គឺ "កម្មាភិបាល" មិនល្អរបស់បកក បានប្រព្រឹត្តបទល្មើសដែល

ចូលរួម" ដោយបុគ្គលនានានៅក្នុងក្រុមប្រឆាំង ដែលរហូតដល់ពេលមួយបានបង្កជម្លោះប្រដាប់អាវុធ ភស្តុតាងដែលបានស្នើនៅក្នុងសំណើមិនបានលើកឡើងពីមូលដ្ឋានថ្មីសម្រាប់បណ្តឹងសាទុក្ខនោះទេ ក៏ប៉ុន្តែបែរជាបង្ហាញបន្ថែមអំពីកំហុសដែលបានជំទាស់នៅក្នុងបណ្តឹងសាទុក្ខ។

១២. បន្ថែមពីលើនេះទៀតនោះ ដោយផ្ទុយពីការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណី[19] សំណើរបស់មេធាវីការពារក្តីគឺគោរពយ៉ាងត្រឹមត្រូវទៅលើវិធាន។ ដូចដែលវិធានសម្រាប់នីតិវិធីគឺវិធាន ១០៨(៧) តម្រូវឲ្យមេធាវីការពារក្តីភ្ជាប់សំណើសុំភស្តុតាងបន្ថែមទៅនឹងសេចក្តីសម្រេចនៅក្នុងសាលក្រមដែលត្រូវបានជំទាស់ គឺមិនមែនមូលដ្ឋាននៃបណ្តឹងសាទុក្ខណាមួយនោះទេ។ ទោះជានៅក្នុងវិធីណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលរក្សាឆន្ទានុសិទ្ធិរបស់ខ្លួនទាំងស្រុង ក្នុងការពិនិត្យទៅលើភស្តុតាងបន្ថែមនៅក្រោមវិធាន ១០៤(១) "នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ ដោយត្រូវពិចារណាលើកាលៈទេសៈជាក់លាក់នៃរឿងក្តី" និង "ត្រូវពិចារណាលើបញ្ហាថាតើ ភស្តុតាងនេះនឹងជួយក្នុងការស្វែងរកការពិតដែរឬយ៉ាងណា"[20]។

## គ. អង្គជំនុំជម្រះសាលាដំបូងពិតជាផ្អែកលើអំណាចដោយសន្មត់និង ការទទួលខុសត្រូវលើបុគ្គលនៅក្រោមបង្គាប់របស់ នួន ជា ក្នុងការចេញសាលក្រម

១៣. ដើមបណ្តឹងរដ្ឋប្បវេណីហាក់ដូចជាជឿជាក់ថា សំណើសុំភស្តុតាងគឺដើម្បីជំទាស់ទៅនឹងការដាក់ទោសដោយសន្មត់លើ នួន ជា ដែលជាថ្នាក់លើមួយរូប[21]។ ជាថ្មីម្តងទៀតចម្លើយតបដើមបណ្តឹងរដ្ឋប្បវេណី យល់ខុសអំពីអំណះអំណាងនៅក្នុងសំណើ។ ភស្តុតាងដែលស្នើដែលជំទាស់នោះគឺ ការរកឃើញផ្អែកអង្គហេតុ និង ច្បាប់ ដែលថា នួន ជា ប្រើប្រាស់អំណាច

---

ជាផ្នែកមួយនៃការប្រឆាំង និង ក្បត់បក្ស" "បញ្ហានោះគឺថា រស់ ញឹម អាច ឬ នឹងបានធ្វើដោយឯករាជពីបំណងរបស់ ប៉ុល ពត និង នួន ជា")។

[19] ឯកសារ **F2/8/1**ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២៣។

[20] ឯកសារ **F2/5** "សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ" ថ្ងៃទី ២៩ ឧសភា ឆ្នាំ២០១៥ កថាខណ្ឌ ១៧។

[21] ឯកសារ **F2/8/1**ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២៤។

របស់ខ្លួន និង គ្រប់គ្រងលើកម្មាភិបាល បកក ដទៃទៀត ជាពិសេសសមាជិកគណៈអចិន្ត្រៃយ៍ ដូចជា វស់ ញឹម និង សោ ភឹម[22]។

១៤. ផ្ទុយទៅនឹងការលើកឡើងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះពិតជាយោងទៅនឹងការរកឃើញ អំណាច *de jure* ឬ *de facto* របស់ នួន ជា សម្រាប់ការដាក់ទោស។ ការរកឃើញអំពីអង្គហេតុ និងច្បាប់ទាក់ទងនឹងអត្ថិភាព *de jure* ឬ *de facto* របស់ នួន ជា លើកម្មាភិបាល បកក ត្រូវបានកំណត់នៅក្នុងការវិភាគរបស់អង្គជំនុំជម្រះអំពីតួនាទីទទួលខុសត្រូវរបស់ នួន ជា ក្នុងការចេញបញ្ជា[23] និង ញុះញង់[24]។

១៥. ការរកឃើញនៅក្រោយនេះត្រូវបានពិចារណាយ៉ាងច្បាស់ដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងការវិភាគរបស់ខ្លួនអំពីការចូលរួមរបស់ នួន ជា នៅក្នុងសហឧក្រិដ្ឋកម្មរួម[25]។ អំណះអំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលថា "ការគ្រប់គ្រងដ៏មានប្រសិទ្ធិភាពរបស់ នួន ជា ទៅអ្នកនៅក្រោមបង្គាប់មានវិសាលភាពបែបណា ក៏មិនអាចយកមកធ្វើជាសំអាងសម្រាប់ការជំទាស់ដែលពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋាននៃការផ្ដន្ទាទោសពីបទសហឧក្រិដ្ឋកម្មរួមដែរ"[26] ដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណីបកស្រាយសាលក្រមមិនត្រឹមត្រូវ។

១៦. ដោយសារតែអង្គជំនុំជម្រះសាលាដំបូងរកឃើញថា នួន ជា ទទួលខុសត្រូវក្នុងនាមជាថ្នាក់លើបន្ថែមពីលើទៀតនោះគឺសម្រាប់គោលបំណងនៃបណ្ដឹងសាទុក្ខគឺមិនត្រឹមត្រូវដែលថា ការផ្ដន្ទាទោសគឺមិនថិតនៅក្នុងមូលដ្ឋាននោះទេ។ មេធាវីការពារក្ដីពិតជាជំទាស់ទៅនឹងការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើនៅក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូល នឹងបដិសេធនូវរាល់ការផ្ដន្ទាទោសនៅលើមូលដ្ឋាននៃទម្រង់ទទួលខុសត្រូវផ្សេងទៀត។

---

[22] ឯកសារ **F2/8** សំណើលើកទីប្រាំមួយ កថាខណ្ឌ ៥ ដល់ ៦។

[23] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" កថាខណ្ឌ ៨៨៤ ដល់ ៩០៥។

[24] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" កថាខណ្ឌ ៨៨៧ ដល់ ៩០៨។

[25] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" កថាខណ្ឌ ៨៦២ ("អង្គជំនុំជម្រះរកឃើញខាងក្រោមថា នួន ជា បាន រៀបចំផែនការ បញ្ជា ញុះញង់ ផ្ដល់ជំនួយ ក្នុងការប្រព្រឹត្តបទល្មើស [...] ថែមទាំងបង្ហាញទំនាក់ទំនងគ្រប់គ្រាន់រវាងសហចារី និង នួន ជា")។

[26] ឯកសារ **F2/8/1**ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២៦។

**ឃ. ភស្តុតាងដែលស្នើនៅក្នុងសំណើទីប្រាំមួយត្រូវតែទទួលយក ដោយមិនគិតពីវិសាលភាពពេលវេលា**

១៧. ជាចុងបញ្ចប់ ដើមបណ្តឹងរដ្ឋប្បវេណី អះអាងថា ភស្តុតាងបន្ថែមនៅក្រោយខែ ធ្នូ ឆ្នាំ ១៩៧៧ គួរតែមិនត្រូវបានពិចារណាដោយអង្គជំនុំជម្រះតុលាការកំពូលនោះទេ[27]។ អំណះអំណាងនេះគឺមិនត្រឹមត្រូវនោះទេ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងពិតជាបានរកឃើញដោយផ្អែកលើភស្តុតាងដែលមានកាលបរិច្ឆេទរហូតដល់ឆ្នាំ១៩៧៩[28]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង អាចផ្អែកលើភស្តុតាងនៅក្រៅវិសាលភាពពេលវេលានៃសំណុំរឿង ០០២/០១ មេធាវីការពារក្តីក៏អាចប្រើប្រាស់ភស្តុតាងដូចគ្នាដើម្បីជំទាស់ទៅនឹងការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែរ។ នៅក្នុងកាលៈទេសៈណាក៏ដោយ មេធាវីការពារក្តីសូមរំលឹកថា អង្គជំនុំជម្រះតុលាការកំពូលរក្សាឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការពិនិត្យភស្តុតាងដែលជួយដល់ការស្វែងរកការពិត និងដែលបានក្នុងពេលថ្មីៗនេះស្តាប់ចម្លើយសាក្សីដែលផ្តល់សក្ខីកម្មអំពីព្រឹត្តិការណ៍នៅក្រោយខែ ធ្នូ ឆ្នាំ ១៩៧៧[29]។

## III. សេចក្តីសន្និដ្ឋាន

១៨. សម្រាប់ហេតុផលដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលទាំងស្រុងនូវចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Victor KOPPE

[27] ឯកសារ **F2/8/1**ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២៨ ដល់ ២៩។

[28] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" កថាខណ្ឌ ២៩៣ ជើងទំព័រ ៩១០ កថាខណ្ឌ ៣១៩ ជើងទំព័រ ៩៨២ និងកថាខណ្ឌ ៣៤៥ ជើងទំព័រ ១០៤០។

[29] ឯកសារ **F2/5** "សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ"។